**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥១.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់វិទ្យាស្ថានស៊ីអ៊ីអូ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១.-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានស៊ីអ៊ីអូ** សរសេរជាអក្សរកាត់ថា **វ.ស.អ.អ** និងជាភាសាអង់គ្លេសថា CEO Institute សរសេរជាអក្សរកាត់ថា CEO.I។

**មាត្រា២.-**

វិទ្យាស្ថានស៊ីអ៊ីអូ មានទីតាំងស្ថិតនៅ អគារលេខ២ ផ្លូវ៤៨៤ កែងផ្លូវ៩៧ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។ វិទ្យាស្ថានស៊ីអ៊ីអូ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៣.-**

វិទ្យាស្ថានស៊ីអ៊ីអូ ធ្វើការបណ្តុះបណ្តាល ដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិលើកម្រិតជំនាញដូចខាងក្រោម៖

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ២ និង៣ សិក្សារយៈពេល១ឆ្នាំ ២ឆ្នាំ ឬ៣ឆ្នាំ ដែលមានយ៉ាងតិច ៣០ក្រេឌីត(សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ដែលមានយ៉ាងតិច ៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា ឯកទេស ឬសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច ១២០ក្រេឌីត។

**មាត្រា៤.-**

វិទ្យាស្ថានស៊ីអ៊ីអូ ធ្វើការបណ្តុះបណ្តាលលើមុខជំនាញដូចខាងក្រោម៖

- អចលនទ្រព្យ
- ឥណទានធនាគារ
- ធានារ៉ាប់រង
- ពាណិជ្ជកម្មអន្តរជាតិ
- គណនេយ្យ និងហិរញ្ញវត្ថុ
- វិទ្យាសាស្ត្រនយោបាយ
- រចនាប្លង់ និងតុបតែង
- ភាសាបរទេស
- ផលិតផល និងសេវាកម្ម
- ផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ
- បដិសណ្ឋារកិច្ច និងគ្រប់គ្រងទេសចរណ៍
- ការគ្រប់គ្រងបណ្តាញផ្គត់ផ្គង់ពាណិជ្ជកម្ម
- សរសេរកម្មវិធីកុំព្យូទ័រ និងរចនាគេហទំព័រ
- ច្បាប់
- ផលិតភាពយន្ត។

នៅថ្ងៃអនាគត វិទ្យាស្ថាននេះ អាចបើកសាខា ប្តូរទីតាំង ដេប៉ាតឺម៉ង់ថ្មី ឯកទេសថ្មី មហាវិទ្យាល័យ ដំឡើងកម្រិតឬថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ឬបន្ថែមជំនាញផ្សេងៗទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥**

វិទ្យាស្ថានស៊ីអ៊ីអូ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃវិទ្យាស្ថានស៊ីអ៊ីអូ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦.-**

នាយកវិទ្យាស្ថានស៊ីអ៊ីអូ មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានស៊ីអ៊ីអូ និងធានាឱ្យមានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវ ក្នុងការជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានកំណត់អំពីសកម្មភាពនៃការធានាគុណភាពក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ជូននាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានទៀងទាត់តាមការកំណត់។

**មាត្រា៧.-**

សិក្ខាកាម សិស្ស និស្សិតដែលបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះ ត្រូវផ្តល់ឱ្យដោយវិទ្យាស្ថានស៊ីអ៊ីអូ ដែលមានការទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថានស៊ីអ៊ីអូ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញាឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារកាលប្បវត្តិ